**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ១១១ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

នាយកទីចាត់ការគយ និងរដ្ឋាករ អាចពិនិត្យ និងសម្រេចតាមការយល់ឃើញថាចាំបាច់ អនុញ្ញាតឲ្យមានការបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ តាម

សំណើរបស់អ្នកនាំចេញ ឬអ្នកនាំចូល សម្រាប់ការនាំចេញ ឬការនាំចូលទំនិញមួយចំនួនដូចខាងក្រោម ៖

១. ទំនិញប្រកបដោយគ្រោះថ្នាក់ ទំនិញងាយផ្ទុះ ឬឆាបឆេះ ឬទំនិញដែលតម្រូវឲ្យស្ថិតក្រោមលក្ខខណ្ឌដោយឡែកនៃការថែរក្សា ការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន និងការធ្វើសន្និធិ ។

២. ទំនិញនាំចេញជាកសិផល ផល ឬអនុផលព្រៃឈើ ជ័រកៅស៊ូគ្រប់ប្រភេទ ឬផលិតផលនេសាទ ដែលត្រូវផ្ទុកក្នុងកុងតេន័រពិសេស ។

៣. ទំនិញនាំចេញដែលផ្ទុកក្នុងកុងតេន័រគ្រប់ប្រភេទរបស់ក្រុមហ៊ុនវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**ប្រការ ២.-**

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវសុំការសម្រេចជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់រាល់សំណើសុំបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ ដោយផ្អែកលើមូលហេតុផ្សេងទៀត ក្រៅពីមានចែងក្នុងប្រការ ១ ខាងលើ ។ ការសម្រេចដូចនេះ ត្រូវបញ្ជាក់នូវលក្ខខណ្ឌដែលទម្រង់ការគយត្រូវបំពេញ ។

សំណើសុំការអនុញ្ញាតដូចខាងលើ ត្រូវមានការពន្យល់អំពី ហេតុផលនៃសំណើ និងត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់នូវទីតាំង ដែលទម្រង់ការគយត្រូវបំពេញ ។

**ប្រការ ៣.-**

មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ច អាចគិតបន្ទុកចំណាយលើសេវាកម្មទាំងនេះ រួមមាន ចំណាយក្នុងការធ្វើដំណើរ និងការស្នាក់នៅ និងប្រសិនបើមានត្រូវគិតកម្រៃការងារក្រៅម៉ោង ដោយអនុលោមតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៥
- សភាពាណិជ្ជកម្មកម្ពុជា " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ